ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ទៅជា វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យនៃការ បង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ទៅជា **"វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ"** សរសេរជាអក្សរកាត់ថា **"វ.ព.ក.ធ."** ជាភាសាអង់គ្លេសថា Polytechnic Institute of Kampong Thom Province សរសេរជាអក្សរកាត់ថា "P.I.K.T."។

**មាត្រា២ .-**

វ.ព.ក.ធ. មានទីតាំងស្ថិតនៅភូមិអាចារ្យលាក់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

វ.ព.ក.ធ. ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ លើកម្រិតជំនាញ ដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ .-**

វ.ព.ក.ធ. មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ វ.ព.ក.ធ.។

សមាសភាព និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

វ.ព.ក.ធ. ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួនតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

វ.ព.ក.ធ. មានដេប៉ាតឺម៉ង់ និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះ វ.ព.ក.ធ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

វ.ព.ក.ធ. អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួន សម្រាប់ជួយបំពេញការងារ។

**មាត្រា៧ .-**

វ.ព.ក.ធ. មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៨ .-**

ការចំណាយសម្រាប់ដំណើរការរបស់ វ.ព.ក.ធ. ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

វ.ព.ក.ធ. មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

មន្ត្រីរាជការដែលបាន និងកំពុងបំពេញការងារនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ ត្រូវផ្ទេរទៅបម្រើការងារនៅ វ.ព.ក.ធ. ដោយរក្សាទុកតួនាទីនៅដដែលរហូតដល់មានការតែងតាំងសារជាថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១០ .-**

វ.ព.ក.ធ. មានតួនាទីជាសេនាធិការឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ច ដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំ និងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាង និងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រី និងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- កៀរគរធនធានពីប្រភពផ្សេងៗទៀត សម្រាប់ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវ
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឱ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១១ .-**

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ វ.ព.ក.ធ. ដែលមានការទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ៥ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ធំ
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ